# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ខែកុម្ភៈ-មីនា ឆ្នាំ២០១៩ / February-March 2019**

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៦ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៦ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៧ |
| ១.៦. វិស័យទេសចរណ៍/Tourism | ៨ |
| ១.៧. វិស័យសំណង់/Construction | ៩ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices** | **៩** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ៩ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ៩ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១០ |
| **៣. ឧបសម្ព័ន្ធ** | **១១** |

## **ខ្លឹមសារសង្ខេប / Executive summary**

១. ក្នុងត្រីមាសទី១ ដើមឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានកំណើន ១,៩% ជាមធ្យម ទាបជាងក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៨ ដែលមានអត្រា ២,២%។ **ការរក្សាបានអត្រាកំណើនទាបនេះ ដោយសារការធ្លាក់ចុះនៃសន្ទស្សន៍ថ្លៃក្រុមទំនិញដឹកជញ្ជូន (ប្រេងសាំងធម្មតា និងម៉ាស៊ូត) ប្រមាណ ៣,៨% ជាមធ្យម ក្នុងត្រីមាសទី១ ឆ្នាំ២០១៩** ។ យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ ប្រេងសាំងធម្មតា និងម៉ាស៊ូតថ្លៃជាមធ្យម ៣ ៤៥០រៀល/លីត្រ និង ៣ ៤៣០រៀល/លីត្រ រៀងគ្នា ទាបជាងថ្លៃមធ្យមក្នុងរយៈពេលដូចគ្នាឆ្នាំមុន (៣ ៨៨០រៀល/លីត្រ និង ៣ ៦៦០រៀល/លីត្រ)។ ការធ្លាក់ចុះថ្លៃនេះ គឺស្របគ្នាទៅនឹងការធ្លាក់ចុះថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិផងដែរ។

២. *ធនាគារ÷* គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៩ ប្រាក់បញ្ញើពីអតិថិជននៃធនាគារប្រាក់បញ្ញើមានចំនួន ៨១,៥ទ្រីលានរៀល បានកើនឡើង ២៦% ធៀបនឹង១ឆ្នាំមុន ក្នុងនោះប្រាក់បញ្ញើរូបិយប័ណ្ណមាន ៧៧,៣ ទ្រីលានរៀល កើនឡើង ២៦,៩% ធៀបនឹង១ឆ្នាំមុន។ ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ២ទ្រីលានរៀល បានកើនឡើង ៤៧,៧% ធៀបនឹង១ឆ្នាំមុន។ ដើមទុនធនាគារប្រាក់បញ្ញើបានបន្តរក្សាកំណើនខ្ពស់នាដើមឆ្នាំ២០១៩ និងក្នុងឆ្នាំ២០១៨កន្លងទៅ ដែលឆ្លុះបញ្ចាំងអំពីសុខភាពរឹងមាំរបស់វិស័យធនាគារនៅកម្ពុជា។ *ការផ្គត់ផ្គង់រូបិយវត្ថុ÷* រូបិយវត្ថុទូទៅ M2 មានចំនួន ៩១,៣ទ្រីលានរៀល បានកើនឡើង ២៤,៨% ធៀបនឹង១ឆ្នាំមុន ក្នុងនោះប្រាក់រៀលចរាចរលើទីផ្សារមានចំនួន ១៤ទ្រីលានរៀល កើនឡើង ១៤,២% ធៀបនឹង១ឆ្នាំមុន។ កំណើនរូបិយវត្ថុទូទៅមាននិន្នាការស្របទៅនឹងកំណើនប្រាក់ចំណូលប្រជាជន ខណៈដែលសេដ្ឋកិច្ចបន្តមានកំណើនខ្ពស់ និងរក្សាបានអតិផរណាក្នុងកម្រិតទាបដែលអាចគ្រប់គ្រងបាន។

៣. ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ តម្លៃជួញដូរមូលបត្រកម្មសិទ្ធិ សរុបមានចំនួន ១២,៧ប៊ីលានរៀល កើនឡើង ៧ដងធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ នៅក្នុងខែមករា ដើមឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីអំពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ក្នុងគោលបំណងលើកស្ទួយការអភិវឌ្ឍបន្ថែមទៀតក្នុងវិស័យមូលបត្រនៅកម្ពុជា។

**៤. ក្នុងរយៈពេល ៣ខែ ដើមឆ្នាំ២០១៩នេះ ការនាំចេញមានទំហំទឹកប្រាក់សរុប ៣ ២២៩ លានដុល្លារ កើនឡើង ១៣,៥% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។** ចំណែកឯ ការនាំចូលមានទំហំទឹកប្រាក់សរុបចំនួនប្រមាណ ៤ ៥៨៨ លានដុល្លារ កើនឡើង ២១,២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ **បើពិនិត្យមើលតាមទំហំទឹកប្រាក់ ការកើនឡើងនៃការនាំចូលគឺដោយសារ កំណើននៃបរិក្ខាសំណង់ ប្រេងឥន្ធនៈ និងគ្រឿងយន្ត ប្រមាណ ៥១% ៩៣,៣% និង ៤១,៦% រៀងគ្នា។**

៥. តាមទិន្នន័យផ្លូវការបឋមពីរតនាគារជាតិ ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសរុបបានចំនួន **៤ ៩២៦,៨** ប៊ីលានរៀល ឬស្មើនឹង **២៤,៩%** នៃច្បាប់ថវិកាឆ្នាំ២០១៩ បានកើនឡើង **១៣,១%** ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ កំណើននេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃប្រភេទចំណូលមួយចំនួនដូចជា ពន្ធប្រយោល (១២,១%) ពន្ធពីពាណិជ្ជកម្មក្រៅប្រទេស (១៣,៨%) និង មិនមែនសារពើពន្ធ (៥១,១%)។ ចំណែកឯ ការអនុវត្តចំណាយសរុបបានចំនួន **៣ ៧១៣,៧** ប៊ីលានរៀល ឬស្មើនឹង **១៤,៩%** នៃច្បាប់ថវិកា២០១៩ បានកើនឡើង **៣,៦%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ រីឯ ចំណាយចរន្តអនុវត្តបានចំនួន **២ ៨៦៥,៩** ប៊ីលានរៀល កើនឡើង **៣,៥%** ក្នុងនោះរួមមាន ចំណាយលើបៀវត្ស ១ ៨១៣,៨ ប៊ីលានរៀល និងចំណាយផ្សេងៗ ៨៩០,៥ ប៊ីលានរៀល។

**៦.** ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន ៦៣ គម្រោង មានទុនវិនិយោគប្រមាណ **១ ៩៣៦** លានដុល្លារអាមេរិក កើនឡើង ៣ដង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើនខ្ពស់នេះ ដោយសារមានការបោះទុនវិនិយោគក្នុងខែកុម្ភៈ ឆ្នាំ២០១៩ លើគម្រោងធំៗចំនួន ២ ដូចជា គម្រោងវិនិយោគលើមជ្ឈមណ្ឌលទេសចរណ៍ និងទីក្រុងទេសចរណ៍។

**៧.** ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ សំណើសុំសាងសង់សរុបមានចំនួន ៩៨៩ គម្រោង កើនឡើង ១១០ គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និង មានកំណើនប្រមាណជាង ២ដង បើគិតតាមផ្ទៃក្រឡា និងទុនវិនិយោគ។ **តាមរយៈនិន្នាការកំណើននេះ យើងអាចសន្និដ្ឋានបានថា វិស័យសំណង់នឹងនៅតែមានស្ថានភាពល្អប្រសើរក្នុងឆ្នាំ២០១៩នេះ។**

**៨.** ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបប្រមាណជាង ១ លាន ៨ សែននាក់ កើនឡើង ៩,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះ ភ្ញៀវទេសចរចិនមានចំនួនប្រមាណជាង ៦៨ម៉ឺននាក់ ឬស្មើនឹង ៣៦,៤% នៃភ្ញៀវទេសចរសរុប (កើនឡើង ៣៥,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន), ភ្ញៀវទេសចរវៀតណាម ៩,៩% និងបន្តបន្ទាប់ រួមមាន ឡាវ ថៃ កូរ៉េ ជប៉ុន និងម៉ាឡេស៊ី។ **តាមរយៈនិន្នាការនេះ អាចបង្ហាញថាចំនួនភ្ញៀវទេសចរណ៍អន្តរជាតិនឹងបន្តកើនឡើងនៅឆ្នាំ២០១៩នេះ រួមផ្សំទាំងកត្តាជំរុញមួយចំនួន ដូចជា (១). ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចក្នុងប្រទេស និងតំបន់ (២). ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និង (៣). ការបន្តកែលម្អតំបន់ទេសចរណ៍ឱ្យកាន់តែប្រសើរ។**

**៩.** ក្នុងខែមីនា ឆ្នាំ២០១៩ ប្រេងឆៅ **(Brent)** ថ្លៃ ៦៧,៦ ដុល្លារ/បារ៉ែល កើនថ្លៃ ១,៥៥ ដុល្លារ/បារ៉ែល ធៀបនឹងខែមុន ដោយសារផលប៉ះពាល់ពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើប្រទេសអ៊ីរ៉ង់ និងវេណេស៊ុយអេឡា ចាប់តាំងពីចុងឆ្នាំ២០១៨មក។ **អង្ករនាំចេញរបស់កម្ពុជា (ខ្ទេច ៥%)** នៅតែរក្សាថ្លៃបាន ៤៦៥ ដុល្លារ/តោន ដូចទៅនឹងខែកុម្ភៈកន្លងទៅ។ ការនាំចេញអង្ករគ្រប់ប្រភេទ ទៅទីផ្សារអឺរ៉ុប បានជិត ៤៣,១ ពាន់តោន ***បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ពោលគឺ ៤១,៩% ក្នុងត្រីមាសទី១កន្លងទៅនេះ ធៀបនឹងត្រីមាសទី១ឆ្នាំមុន។ ដើម្បីជួយដោះស្រាយការធ្លាក់ចុះបរិមាណនាំចេញអង្ករទៅទីផ្សារអឺរ៉ុប និងលើកកម្ពស់ការប្រកួតប្រជែងលើទីផ្សារអន្តរជាតិ រាជរដ្ឋាភិបាលបានព្យាយាមពង្រីកទីផ្សារបន្ថែមជូនប្រជាកសិករ ដោយគិតត្រឹមត្រីមាសទី១នេះ កម្ពុជាបាននាំចេញអង្ករទៅទីផ្សារចិនចំនួន ៧៥,២ ពាន់តោន (ស្មើនឹង៤២%នៃការនាំចេញសរុប) បានកើនឡើង ៧៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។*** **កៅស៊ូឆៅស្តង់ដារ TSR20** លើទីផ្សារអាស៊ី ថ្លៃ ១ ៥២០ ដុល្លារ/តោន បានកើន ២០ ដុល្លារ/តោន ធៀបនឹងខែមុន។ **ឥទ្ធិពលសង្គ្រាមពាណិជ្ជកម្មរវាងប្រទេសចិន និងអាមេរិក និងការរំពឹងទុករបស់សមាគមន៍នៃប្រទេសផលិតកៅស៊ូ ធម្មជាតិ (ANRPC) នៅតែជាកត្តាសំខាន់ក្នុងកំណើនថ្លៃ និងតម្រូវការកៅស៊ូពិភពលោក។**

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Construction Approval in Nationwide (0000m2)**




Source: Min. LMUC

**Tourist Arrivals ('000 persons)**



Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបម្រុងបរទេស (Inflation, M2 and Foreign Reserve)

## Net Foreign Reserve (Mn US$)




Source: NBC

## Inflation (Montly)




Source: NIS

## Inflation (Annual)




Source: NIS

## Inflation of Main Group Items (monthly)




Source: NIS

## Inflation of main group Items (Year on Year)




Source: NIS

## Broad Money M2 (Bn KHR)




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

### Exchange rate R/100Đ and R/B




Source: IMF

### Exchang Rate Mal-Ringgit/$ and Phi-Peso/$




Source: IMF

### CPI and Exchange rate R/$




Source: IMF

### Exchange rate EU Euro/US$ and Pound/US$




Source: IMF

### Exchange rate Aus-$ and HK-$




Source: IMF

### Exchange rate Sing-$ and Yen-$




Source: IMF

## ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)


















# ការអនុវត្តថវិកា (Budget)

ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៨-២០១៩




ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៨-២០១៩




ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៨-២០១៩




Source: MEF

ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៨-២០១៩




ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៨-២០១៩




ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៨-២០១៩



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Annual Private investment CDC Approval (%)**




Source: CDC

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

**FDI and Direct Investment Abroad, 2011Q1~2017Q1 (Quarterly, USD Mn)**




Source: CEIC

# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

## <u>កំណត់សម្គាល់</u>

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និងSTR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាបហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាមនិងចិន។
- កៅស៊ូRSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុសម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ ប្រភេទប្រេងBrent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40o API
- Brent 38o API
- Dubai 32o API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧  ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*